ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ

## ស្តីពី

# វិស័យវប្បធម៌

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤

**រៀបចំដោយ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ

# ស្តីពី

# វិស័យវប្បធម៌

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤

រៀបចំដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

# មាតិកា


**១- សេចក្តីផ្តើម** ........................................ ១

**២- ចក្ខុវិស័យ** ........................................ ២

**៣- គោលបំណងនិងគោលដៅ** ........................................ ២

៣.១- គោលបំណង ........................................ ២

៣.២- គោលដៅ ........................................ ២

**៤- យុទ្ធសាស្ត្រ** ........................................ ២

៤.១- ការថែរក្សា ការពារ និងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ........................................ ២

៤.២- ការប្រើប្រាស់សក្តានុពលវប្បធម៌ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច ........................................ ៣

៤.៣- ការលើកស្ទួយនិងការជំរុញឧស្សាហកម្មវប្បធម៌ ........................................ ៣

៤.៤- ការគាំទ្រដល់ដៃគូវិស័យវប្បធម៌ ........................................ ៥

៤.៥- ការគាំទ្រដល់ការបង្កើតទីផ្សារខាងវិស័យវប្បធម៌ ........................................ ៥

៤.៦- ការអប់រំនិងការបណ្តុះបណ្តាល ........................................ ៦

៤.៧- កិច្ចសហប្រតិបត្តិការជាមួយគ្រប់ស្ថាប័ននិងដៃគូនានា ........................................ ៦

**៥- ផែនការសកម្មភាព** ........................................ ៦

៥.១ - ការបង្កើតយន្តការ ........................................ ៦

៥.២ - ការបង្កើតក្របខ័ណ្ឌគតិយុត្ត ........................................ ៦

៥.៣ - ការគាំទ្រផ្នែកហិរញ្ញវត្ថុ ........................................ ៧

៥.៤ - ការបណ្តុះបណ្តាលធនធានមនុស្ស ........................................ ៧

៥.៥ - ដំណើរការអនុវត្តគម្រោង ........................................ ៧

**៦- ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ** ........................................ ៧

**៧- សេចក្តីសន្និដ្ឋាន** ........................................ ៧

**សន្ទានុក្រម**

## ១- សេចក្តីផ្តើម

បេតិកភណ្ឌវប្បធម៌ដ៏សម្បូរបែបទាំងរូបីទាំងអរូបីដែលបុព្វបុរសយើងបានបន្សល់ទុករហូតដល់សព្វថ្ងៃ មិនត្រឹមតែជាសក្ខីភាពបង្ហាញពីភាពរុងរឿងថ្កុំថ្កើងគួរជាទីស្ញប់ស្ញែងនៃមនុស្សជាតិប៉ុណ្ណោះទេ ថែមទាំងមានតួនាទីដ៏សំខាន់ក្នុងការផ្សារភ្ជាប់នូវទំនាក់ទំនងរវាងមនុស្សនិងមនុស្ស សង្គមនិងសង្គម ព្រមទាំងរួមចំណែកក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិនិងភាពសុខសាន្តរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាពទៀតផង។ ក៏ប៉ុន្តែ ក្នុងចរន្តនៃសាកលភាវូបនីយកម្ម សម័យបច្ចេកវិទ្យាទំនើបបានញ៉ាំងឲ្យសង្គមមានការវិវត្តយ៉ាងគំហុក ដែលជាហេតុធ្វើឲ្យមរតកវប្បធម៌ដ៏មានតម្លៃទទួលរងនូវការប្រឈមយ៉ាងខ្លាំងរហូតដល់អាចនឹងឈានទៅបាត់បង់ដោយអន្ទើៗ។

អាស្រ័យហេតុនេះ ការចូលរួមក្នុងការថែរក្សា ការការពារ ការអភិរក្សបេតិកភណ្ឌវប្បធម៌ជាតិឲ្យបានគង់វង្ស និងការចូលរួមគាំទ្រឲ្យមានការវិនិយោគលើវិស័យវប្បធម៌ ដើម្បីកំណើនសេដ្ឋកិច្ច ព្រមទាំងការបង្កើតឲ្យមានទីផ្សារការងារ គឺជាកិច្ចការចាំបាច់ចំពោះមុខ។

ដើម្បីសម្រេចបាននូវរាល់កិច្ចការទាំងអស់នេះ ទាមទារឲ្យមានការរៀបចំផ្តល់ឱកាសសមស្រប ដូចជាការជួយផ្តល់ហិរញ្ញប្បទាន ការជំរុញការកសាងបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិស័យវប្បធម៌ ការរៀបចំយន្តការនិងបទដ្ឋានគតិយុត្តចាំបាច់នានា ដែលជាចលករក្នុងការជួយជំរុញនិងជួយគាំទ្រ លើកទឹកចិត្តដល់ការផលិត ការប្រើប្រាស់ និងការធានាទីផ្សារនៃផលិតផលសេវាកម្មវប្បធម៌និងការចូលរួមសហការពីគ្រប់បណ្តាអង្គភាព ស្ថាប័នពាក់ព័ន្ធ ពិសេសក្រសួងវប្បធម៌និងវិចិត្រសិល្បៈដែលជាស្ថាប័នមានបេសកកម្មដឹកនាំនិងគ្រប់គ្រងវិស័យវប្បធម៌និងវិចិត្រសិល្បៈនៃព្រះរាជាណាចក្រកម្ពុជា។

គោលនយោបាយជាតិស្តីពីវិស័យវប្បធម៌នេះ គឺជាមូលដ្ឋានគ្រឹះនិងជាត្រីវិស័យក្នុងការនាំឆ្ពោះទៅដល់ការផ្សារភ្ជាប់វិស័យវប្បធម៌ទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការពង្រឹងអត្តសញ្ញាណជាតិ ការលើកស្ទួយសីលធម៌និងកិត្យានុភាពជាតិ ការរក្សាការពារចំណេះដឹងប្រពៃណី និងការលើកស្ទួយភាពផ្សេងៗគ្នានៃវប្បធម៌។

**២- ចក្ខុវិស័យ**

គោលនយោបាយជាតិស្តីពីវិស័យវប្បធម៌នេះមានចក្ខុវិស័យអភិរក្សនិងអភិវឌ្ឍវប្បធម៌ជាតិដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

**៣- គោលបំណងនិងគោលដៅ**

គោលបំណងនិងគោលដៅនៃគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌រួមមាន៖

**៣.១- គោលបំណង**

- ធានាសុវត្ថិភាព សុខដុមភាព និរន្តរភាព និងវឌ្ឍនភាពវប្បធម៌ជាតិ
- លើកកម្ពស់សីលធម៌ គុណធម៌ ប្រពៃណីជាតិ និងពង្រឹងអត្តសញ្ញាណនិងកិត្យានុភាពជាតិ
- រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម។

**៣.២- គោលដៅ**

- ថែរក្សា ការពារ និងអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ជាតិឲ្យស្ថិតស្ថេរគង់វង្សជានិរន្តរ៍
- រៀបចំផែនការ យន្តការ និងបទដ្ឋានគតិយុត្ត ដើម្បីធានាដល់ការអភិរក្សនិងអភិវឌ្ឍវិស័យវប្បធម៌
- ធ្វើការអប់រំនិងបណ្តុះបណ្តាលដោយឈរលើគោលការណ៍ "អប់រំដើម្បីវប្បធម៌ វប្បធម៌ដើម្បីអប់រំ"
- ផលិតនិងរកទីផ្សារវប្បធម៌ឲ្យកាន់តែទូលាយ ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម
- អភិវឌ្ឍសហគមន៍ដោយធ្វើឲ្យអ្នកពាក់ព័ន្ធទទួលបានផលប្រយោជន៍ពីវប្បធម៌ប្រកបដោយសមធម៌
- បង្កើតថ្មីលើផលិតផលវប្បធម៌គ្រប់ប្រភេទ ពិសេស ផ្នែកឧស្សាហកម្មច្នៃប្រឌិត
- រៀបចំព្រឹត្តិការណ៍ផ្សេងៗទាក់ទងនឹងវប្បធម៌
- ពង្រឹងនិងពង្រីកការផ្លាស់ប្តូរព័ត៌មាន ចំណេះដឹង ចំណេះធ្វើ បទពិសោធ បច្ចេកទេស និងការវិនិយោគលើវិស័យវប្បធម៌
- កាត់បន្ថយវប្បធម៌អវិជ្ជមានដែលមានផលប៉ះពាល់ដល់សង្គម
- ផ្តល់ឱកាសឲ្យប្រជាជន ពិសេស យុវជននិងកុមារមានលទ្ធភាពចូលរួមក្នុងសកម្មភាពវប្បធម៌និងទទួលផលពីវិស័យវប្បធម៌ប្រកបដោយសមធម៌
- បង្កើនការយល់ដឹងពីតម្លៃពិតនៃវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់របស់ជាតិ និងភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌
- បង្កើនការយកចិត្តទុកដាក់លើកកម្ពស់ការងារផ្នែកអក្សរសាស្ត្រនិងអក្សរសិល្ប៍។

**៤- យុទ្ធសាស្ត្រ**

ដើម្បីសម្រេចបានគោលបំណងនិងគោលដៅខាងលើ យុទ្ធសាស្ត្រសំខាន់ៗមាន៖

៤.១- ការថែរក្សា ការពារ និងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ដោយផ្តោតទៅលើសកម្មភាពដូចខាងក្រោម៖

- ធ្វើការស្រាវជ្រាវ ផ្សព្វផ្សាយ និងទាមទារយកមកវិញនូវវត្ថុបុរាណខ្មែរដែលត្រូវបានលួចនិងកាន់កាប់ដោយខុសច្បាប់នៅក្នុងនិងក្រៅប្រទេស
- ធ្វើបញ្ជីសារពើភណ្ឌនិងធ្វើផែនទីកំណត់ធនធានវប្បធម៌
- ផ្តល់មធ្យោបាយបច្ចេកទេសនិងថវិកាចំពោះគម្រោងសិក្សាស្រាវជ្រាវនិងអភិរក្សបេតិកភណ្ឌ
- ថែទាំនិងលើកស្ទួយវប្បធម៌ជនជាតិដើមភាគតិច
- សិក្សាស្រាវជ្រាវអំពីបេតិកភណ្ឌវប្បធម៌ដែលកំពុងប្រឈមនឹងគ្រោះថ្នាក់ ដែលនឹងឈានទៅដល់ការបាត់បង់ដើម្បីធ្វើការអភិរក្ស
- ដកស្រង់បទពិសោធចេញពីគម្រោងសហប្រតិបត្តិការអន្តរជាតិនានា ជាពិសេសកិច្ចសហប្រតិបត្តិការអន្តរជាតិដែលបាននិងកំពុងអនុវត្តក្នុងក្របខ័ណ្ឌដែលជាលទ្ធផលនៃការចុះបញ្ជីសម្បត្តិបេតិកភណ្ឌវប្បធម៌របស់កម្ពុជា ជាសម្បត្តិបេតិកភណ្ឌពិភពលោក
- ចងក្រងឯកសារសម្រាប់ជាមូលដ្ឋានបម្រើដល់ការសិក្សាស្រាវជ្រាវ ផ្សព្វផ្សាយ និងអប់រំ
- បង្កើតមណ្ឌលវប្បធម៌នៅតាមបណ្តាខេត្ត ដើម្បីបង្ហាញពីប្រពៃណី ជំនឿ និងរបៀបរបបរស់នៅរបស់ប្រជាជនខ្មែរ និងបង្ហាញអំពីភាពសម្បូរបែបនៃវប្បធម៌របស់ព្រះរាជាណាចក្រកម្ពុជា
- បង្កើតឲ្យមានបណ្តាញទំនាក់ទំនងរវាងសារមន្ទីរនិងមណ្ឌលវប្បធម៌ ដើម្បីបង្កើនសមត្ថភាពនិងចែករំលែកចំណេះដឹងពីគ្នាទៅវិញទៅមក
- ជំរុញឲ្យមានការពិគ្រោះយោបល់ពីសហគមន៍តាមមូលដ្ឋានក្នុងបំណងប្រែក្លាយមណ្ឌលវប្បធម៌ឲ្យទៅជាកន្លែងជួបជុំផ្លាស់ប្តូរយោបល់នានាពាក់ព័ន្ធនឹងវិស័យវប្បធម៌
- ពង្រឹងនិងពង្រីកវប្បធម៌នៅតាមវត្តអារាម។

**៤.២- ការប្រើប្រាស់សក្តានុពលវប្បធម៌ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចដោយផ្តោតទៅលើសកម្មភាពដូចខាងក្រោម៖**

- លើកកម្ពស់ការអភិរក្សនិងអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ដើម្បីទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិ
- ជំរុញកម្ពុជាឲ្យក្លាយជាមជ្ឈមណ្ឌលផ្សព្វផ្សាយសិល្បទស្សនីយភាព ផលិតផលវប្បធម៌និងជាដែនដីនៃការថតភាពយន្តជាតិនិងបរទេស
- បង្កើតឱកាសការងារលើវិស័យវប្បធម៌ដើម្បីចូលរួមជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

**៤.៣- ការលើកស្ទួយនិងការជំរុញឧស្សាហកម្មវប្បធម៌ដោយផ្តោតទៅលើសកម្មភាពដូចខាងក្រោម៖**

- គាំទ្រនិងលើកទឹកចិត្តដល់ការបង្កើតស្នាដៃថ្មីវិជ្ជមានលើគ្រប់ផ្នែកដូចជាតន្ត្រី សោត-ទស្សន៍ ភាពយន្ត ការបោះពុម្ព សិល្បទស្សនីយភាព សិប្បកម្ម វិចិត្រកម្ម តម្បាញប្រពៃណី ការច្នៃម៉ូដ និងស្ថាបត្យកម្ម ...
- រៀបចំមហោស្រពតាំងបង្ហាញស្នាដៃថ្មីនិងផលិតផលឧស្សាហកម្មច្នៃប្រឌិត
- កំណត់និងថែរក្សាការពារអំពីរបៀបរស់នៅ ចំណេះដឹង ប្រពៃណីតាមតំបន់និងតាមបណ្តារាជធានី ខេត្ត
- ជំរុញឲ្យមានការផ្ទេរចំណេះ ជំនាញ ទេពកោសល្យប្រពៃណីទៅយុវជនជំនាន់ក្រោយ
- កំណត់ផលប្រយោជន៍ការអភិវឌ្ឍក្នុងពេលបច្ចុប្បន្ន ដែលអាចជួយដល់ដំណើរការផលិតជាលក្ខណៈប្រពៃណី និងការស្រាវជ្រាវរកទម្រង់ឬរបៀបផ្សេងទៀតដើម្បីបញ្ចូលទៅក្នុងការផលិតជាលក្ខណៈប្រពៃណីនោះ
- ពង្រឹងសីលធម៌និងរបៀបរបបរស់នៅឲ្យបានល្អប្រសើរដើម្បីទទួលបានការនិយមស្រឡាញ់វប្បធម៌ជាតិកាន់តែខ្លាំងឡើង
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការសម្របសម្រួលលើវិធាននានាដែលជាប់ទាក់ទងនឹងផលិតផលវប្បធម៌និងបញ្ហាពាក់ព័ន្ធ
- រៀបចំបង្កើតក្រុមការងារអន្តរក្រសួងមួយដើម្បីធ្វើការដោះស្រាយលើបញ្ហាចម្បងនានាដែលពាក់ព័ន្ធនឹងវិស័យវប្បធម៌ និងធ្វើការកំណត់គោលដៅរួម
- ពង្រឹងសមត្ថភាពអន្តរស្ថាប័នជាតិនិងផ្លាស់ប្តូរបទពិសោធជាមួយស្ថាប័នអន្តរជាតិដែលពាក់ព័ន្ធនឹងវិស័យវប្បធម៌
- ជំរុញនិងលើកទឹកចិត្តដល់ការចូលរួមពីសាធារណជនក្នុងការអភិរក្សនិងអភិវឌ្ឍវប្បធម៌ជាតិ
- គាំទ្របណ្តាសហគមន៍ ដៃគូវប្បធម៌ និងសង្គមស៊ីវិលនៅតាមមូលដ្ឋានដែលបានឬមានបំណងធ្វើសកម្មភាពទាំងឡាយណាដែលស្របតាមគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌
- រៀបចំបង្កើតឲ្យមានយន្តការសម្របសម្រួល«វេទិកាសាធារណៈលើវិស័យវប្បធម៌សិល្បៈ» ដើម្បីផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធនានា ទាំងផ្នែករដ្ឋ ផ្នែកឯកជន សង្គមស៊ីវិល ទាំងអ្នកបណ្តុះបណ្តាល អ្នកប្រកបអាជីពខាងសិល្បៈ ជនជាតិដើមភាគតិច បានជួបប្រជុំពិភាក្សានិងបានចូលរួមចំណែកក្នុងការរៀបចំនិងអនុវត្តនូវគោលនយោបាយវប្បធម៌ដោយឈរលើគោលការណ៍ជាក់ស្តែង
- រៀបចំបង្កើតឲ្យមាននីតិវិធីសម្រាប់ទំនាក់ទំនង និងចែករំលែកព័ត៌មានដល់ភាគីពាក់ព័ន្ធនឹងវិស័យវប្បធម៌
- លើកកម្ពស់ការចូលរួម និងការផ្សព្វផ្សាយសកម្មភាពវប្បធម៌

- គាំទ្រនូវគំនិតផ្តួចផ្តើមល្អៗ ទាំងផ្នែកឯកជន ទាំងសង្គមស៊ីវិល
- រៀបចំឲ្យបានទៀងទាត់នូវព្រឹត្តិការណ៍វប្បធម៌ប្រចាំឆ្នាំដូចជាទិវាវប្បធម៌ជាតិ ពិធីបង្ហោះខ្លែង មហោស្រពសិល្បៈ មហោស្រពម្ហូបអាហារខ្មែរ ការបង្ហាញម៉ូដ និងការប្រឡងចម្រៀង ...។

**៤.៤- ការគាំទ្រដល់ដៃគូវិស័យវប្បធម៌ដោយផ្តោតទៅលើសកម្មភាពដូចខាងក្រោម៖**

- ជួយគាំទ្រនិងបង្កើតឲ្យមានយន្តការទាក់ទាញនិងសម្របសម្រួលចំពោះផ្នែកឯកជន និងសង្គមស៊ីវិល
- បង្កើតឲ្យមានយន្តការជួយសម្របសម្រួលឲ្យសហគ្រិនវប្បធម៌ទាំងឡាយអាចរកប្រភពមូលធនបាន
- លើកទឹកចិត្តនិងគាំទ្រចំពោះការបង្កើតឲ្យមានឧស្សាហកម្មវប្បធម៌ច្នៃប្រឌិត។

**៤.៥- ការគាំទ្រដល់ការបង្កើតទីផ្សារខាងវិស័យវប្បធម៌ដោយផ្តោតលើសកម្មភាពដូចខាងក្រោម៖**

- សិក្សាស្រាវជ្រាវជាប្រចាំអំពីស្ថានភាពទីផ្សារខាងវិស័យវប្បធម៌និងធ្វើការផ្សព្វផ្សាយអំពីលទ្ធផលទាំងនោះ
- ជួយសិល្បករនិងផលិតករក្នុងការរកទីផ្សារ
- ជួយសម្របសម្រួលឲ្យសិល្បករនិងផលិតករបង្កើតនិងបង្កើនផលិតកម្មវប្បធម៌តាមតម្រូវការទីផ្សារ
- បង្កើតសញ្ញាសម្គាល់ផលិតផលវប្បធម៌ដែលមានបញ្ចូលគ្នាទាំងគំនិតបង្កើតថ្មី ទាំងលក្ខណៈជាប្រពៃណី
- គាំទ្រដល់ការធ្វើពាណិជ្ជកម្មផលិតផលវប្បធម៌ និងជួយបង្កើតឲ្យមានបណ្តាញចែកចាយផលិតផល
- ជំរុញឲ្យមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្តបង្កើននូវការយកចិត្តទុកដាក់ជួយសិល្បករនិងផលិតករ
- បោះពុម្ពផ្សព្វផ្សាយអំពីផលិតផលវប្បធម៌ និងពង្រីងការផ្លាស់ប្តូរជាលក្ខណៈអន្តរជាតិ
- លើកទឹកចិត្តឲ្យមានការចូលរួមជាបណ្តាញវប្បធម៌ក្នុងតំបន់
- ពង្រឹងនិងពង្រីកយន្តការគ្រប់គ្រងត្រួតពិនិត្យលើការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាឲ្យបានហ្មត់ចត់និងមាននិរន្តរភាព
- ចាត់វិធានការទប់ស្កាត់ជាប្រចាំចំពោះការលួចនិងការធ្វើចរាចរណ៍ជួញដូរផលិតផលវប្បធម៌ខុសច្បាប់
- សម្រួលការនាំចូលនូវសម្ភារៈបច្ចេកវិទ្យាស្តង់ដានិងស្របច្បាប់ជូនសហគ្រិនប្រកបមុខរបរលើវិស័យវប្បធម៌ថ្មីៗ

**៤.៦- ការអប់រំនិងការបណ្តុះបណ្តាលដោយផ្តោតទៅលើសកម្មភាពដូចខាងក្រោម៖**

- ដាក់បញ្ចូលឲ្យមានការបង្រៀនសិល្បៈ វប្បធម៌ក្នុងកម្មវិធីសិក្សានៅតាមបណ្តាគ្រឹះស្ថានសិក្សា និងសាលាបណ្តុះបណ្តាល ដើម្បីបង្កើនចំណេះដឹងលើវិស័យសិល្បៈ វប្បធម៌ និងផ្តត់គំនិតស្រឡាញ់សម្បត្តិវប្បធម៌ដល់យុវជនជំនាន់ក្រោយ
- គាំទ្រឲ្យមានការបង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញសិល្បៈចំពោះអ្នកសិល្បៈអាជីព
- ធ្វើវិក្រឹតការឯកទេសដល់អ្នកមានអាជីពខាងវិស័យវប្បធម៌
- រៀបចំបង្កើតកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈលើវិស័យវប្បធម៌ ជាអាទិ៍ ការនិពន្ធអក្សរសាស្ត្រ និងអក្សរសិល្ប៍ ផ្នែកសិប្បកម្ម វប្បធម៌ និងសិល្បៈនៅតាមបណ្តារាជធានី ខេត្ត
- កែប្រែឥរិយាបថមន្ត្រីវប្បធម៌ឲ្យបំពេញការងារជាអ្នកគ្រប់គ្រងនិងជាអ្នកផ្តល់សេវាជូនសាធារណជនប្រកបដោយប្រសិទ្ធភាព
- បង្កើនគ្រូសិល្បៈឲ្យបានកាន់តែច្រើននិងធ្វើឲ្យស្ថានភាពការងាររបស់ពួកគាត់កាន់តែប្រសើរឡើង
- លើកកម្ពស់ការចូលរួមរបស់ស្ត្រី ជនពិការ និងជនជាតិដើមភាគតិចក្នុងវិស័យវប្បធម៌។

**៤.៧- កិច្ចសហប្រតិបត្តិការជាមួយគ្រប់ស្ថាប័ននិងដៃគូនានាដោយផ្តោតលើសកម្មភាពដូចខាងក្រោម៖**

- ពង្រឹងនិងពង្រីកទំនាក់ទំនងភាពជាដៃគូដើម្បីថែរក្សានិងអភិវឌ្ឍវប្បធម៌ជាតិទាំងថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ ទាំងថ្នាក់តំបន់ និងពិភពលោក
- បង្កើនការផ្លាស់ប្តូរសកម្មភាពវប្បធម៌ សិល្បៈជាមួយបណ្តាប្រជាជាតិដើម្បីសន្តិភាព សុខដុមភាព និងការអភិវឌ្ឍ
- រៀបចំឲ្យមានសិក្ខាសាលានៅក្នុងប្រទេសនិងនៅបរទេស។

## ៥- ផែនការសកម្មភាព

### ៥.១ - ការបង្កើតយន្តការ

រាជរដ្ឋាភិបាលប្រើប្រាស់យន្តការដែលមានស្រាប់ឬបង្កើតយន្តការថ្មីដែលចាំបាច់ ដើម្បីសម្របសម្រួល ពិគ្រោះយោបល់ និងសហការជាមួយផ្នែកពាក់ព័ន្ធក្នុងការរៀបចំផែនការសកម្មភាពដើម្បីឈានទៅសម្រេចគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌នេះ។

### ៥.២ - ការបង្កើតក្របខ័ណ្ឌគតិយុត្ត

ការអនុវត្តគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌នេះត្រូវរៀបចំឲ្យមានច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីការងារសមស្របតាមវិស័យពាក់ព័ន្ធនានា ដោយកំណត់សកម្មភាពជាក់លាក់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងការពិនិត្យនិងកែសម្រួលច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យវប្បធម៌។

**៥.៣ - ការគាំទ្រផ្នែកហិរញ្ញវត្ថុ**

ដើម្បីអនុវត្តសកម្មភាពក្នុងគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌ ត្រូវប្រើប្រាស់ថវិការបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងវិស័យវប្បធម៌ ជំនួយបច្ចេកទេសរបស់ដៃគូអភិវឌ្ឍ ជំនួយសប្បុរស និងថវិកាបានមកពីប្រភពផ្សេងៗទៀត។

**៥.៤ - ការបណ្តុះបណ្តាលធនធានមនុស្ស**

ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌នេះ ត្រូវយកចិត្តទុកដាក់រៀបចំនិងអនុវត្តគម្រោងកម្មវិធីសិក្សារយៈពេលខ្លី មធ្យម និងវែង ដើម្បីបង្កើនចំណេះដឹងនិងបទពិសោធលើវិស័យវប្បធម៌សម្រាប់អ្នកជំនាន់ក្រោយ និងដើម្បីអភិវឌ្ឍចំណេះដឹងនិងជំនាញដល់មន្ត្រីទទួលបន្ទុកការងារ ។

**៥.៥ - ដំណើរការអនុវត្តគម្រោង**

គោលនយោបាយនេះត្រូវយកមកអនុវត្តក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង ដោយមានការពិគ្រោះយោបល់ពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូវប្បធម៌ ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយជាតិស្របទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។

## ៦- ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

ដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌ឲ្យសម្រេចបានជោគជ័យ ត្រូវរៀបចំបង្កើតយន្តការនិងរចនាសម្ព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដោយសិក្សាវិភាគលើរបាយការណ៍ប្រចាំឆ្នាំលើយោបល់និងបញ្ហាប្រឈមនានាដែលលើកស្នើឡើងដោយភាគីពាក់ព័ន្ធតាមរយៈវេទិកាសាធារណៈលើវិស័យសិល្បៈវប្បធម៌ ព្រមទាំងការវាយតម្លៃរៀងរាល់បីឆ្នាំម្តងចំពោះប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌នេះ។

## ៧- សេចក្តីសន្និដ្ឋាន

គោលនយោបាយជាតិស្តីពីវិស័យវប្បធម៌ គឺជាផែនទីចង្អុលផ្លូវក្នុងការអភិរក្សនិងអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ដ៏មានតម្លៃរបស់ជាតិឲ្យបានគង់វង្សនិងស្ថិតស្ថេរយូរអង្វែង ព្រមទាំងជួយដល់ការប្រើប្រាស់សក្តានុពលវប្បធម៌ដ៏ខ្លាំងក្លារបស់ជាតិក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយប្រសិទ្ធភាពខ្ពស់និងមាននិរន្តរភាព។

# សទ្ទានុក្រម

- **បេតិកភណ្ឌវប្បធម៌ជាតិ** សំដៅដល់សម្បត្តិវប្បធម៌ទាំងរូបីនិងអរូបីរបស់ជាតិ។
- **ប្រឌិតញ្ញាណ** សំដៅដល់គំនិតច្នៃប្រឌិតថ្មីៗនានាទាក់ទងនឹងវស័យវប្បធម៌។
- **ភាពផ្សេងៗគ្នានៃវប្បធម៌** សំដៅដល់ពហុភាពនៃទម្រង់ដែលតាមរយៈនោះ វប្បធម៌ក្រុមមនុស្សនិងសង្គមអាចស្វែងរកឃើញនូវវិញ្ញត្តិរបស់ខ្លួន។ វិញ្ញត្តិទាំងនេះនឹងផ្ទេរបន្តទៅឲ្យគ្នាទៅវិញទៅមកក្នុងចំណោមក្រុមមនុស្សនិងសង្គម ហើយរវាងសង្គមនិងសង្គម។
- **វប្បធម៌** សំដៅដល់ទំនៀមទម្លាប់ប្រពៃណី ផ្នត់គំនិត ជំនឿសាសនា បច្ចេកវិទ្យា និងឥរិយាបថនៃសង្គមមនុស្សឬជាតិសាសន៍មួយ។
- **វប្បធម៌អវិជ្ជមាន** សំដៅដល់អំពើដែលពាក់ព័ន្ធនឹងវិស័យវប្បធម៌ទាំងឡាយណាដែលអាចនឹងនាំឲ្យប៉ះពាល់និងរង្គោះរង្គើដល់វប្បធម៌ប្រពៃណីដ៏ល្អប្រពៃរបស់ជាតិ។
- **វិញ្ញត្តិវប្បធម៌** សំដៅដល់ការបង្ហាញ ឬការសម្ដែងដែលកើតចេញគំនិតច្នៃប្រឌិតរបស់បុគ្គលម្នាក់ៗ របស់ក្រុមមនុស្សនិងសង្គម ហើយមានបង្កប់នូវខ្លឹមសារវប្បធម៌។
- **ឧស្សាហកម្មច្នៃប្រឌិត** សំដៅដល់ឧស្សាហកម្មផលិតដែលកើតចេញពីការច្នៃប្រឌិតទាក់ទងនឹងវិស័យវប្បធម៌ ហើយដែលជួយលើកតម្កើងវប្បធម៌ជាតិនិងសេដ្ឋកិច្ច សង្គម។
- **ឧស្សាហកម្មវប្បធម៌** សំដៅដល់ឧស្សាហកម្មផលិតនិងចែកចាយផលិតផល ឬសេវាកម្មវប្បធម៌។